# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ

**web site: hoksavann.org**

ថ្ងៃទី១៥ កញ្ញា ២០០៥

បុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ ត្រូវពុទ្ធសាសនិកជនខ្មែរតែងធ្វើមុនព្រះសង្ឃចេញព្រះវស្សាចំនួនមួយខែរៀងរាល់ឆ្នាំ គឺចាប់កាន់បិណ្ឌតាមវេន ពីថ្ងៃ១រោជដល់១៤រោចខែភទ្របទ ។ នៅថ្ងៃ១៥រោចជាថ្ងៃភ្ជុំបិណ្ឌ គឺជាថ្ងៃកំណត់ដោយគេធ្វើពិធីបុណ្យនេះរួមគ្នាគ្រប់វេនទាំងអស់ ។ ពាក្យថាបិណ្ឌចេញមកពីភាសាបាលីថាបិណ្ឌំ ប្រែថាដុំបាយ ដូចជាពាក្យថាបិណ្ឌបាត្រ គឺយកដុំបាយទម្លាក់ក្នុងបាត្រ ។ ប៉ុន្តែបាយបាត្រដែលគេធ្វើក្នុងពេលកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ គឺជាដុំបាយដំណើបដែលគេចំអិនលាយខ្ទិះដូងនិងល្ង ឬលាយជាមួយគ្រឿងផ្សំផ្សេងទៀត តាមទម្លាប់អ្នកស្រុក ។ គេរៀបចំបាយបិណ្ឌនៅជុំវិញបាយបត្តបូរ ។ បាយបត្តបូរក៏ធ្វើដូចបាយបិណ្ឌដែរ គ្រាន់តែគេពូតជាពំនូតធំ មានកំពូលស្រួច ហើយគ្របដោយសាជីស្លឹកចេក និងមានដោតទៀនធូបផ្កាភ្ញីផង ។ កន្លែងខ្លះឲ្យន័យថា ពាក្យថាបិណ្ឌគឺចង្ហាន់ដែលពុទ្ធបរិស័ទប្រគេនព្រះសង្ឃឆាន់ក្នុងពិធីបុណ្យ ឧទ្ទិសផលបញ្ជូនទៅញាតិសន្តានមានមាតាបីតាជាដើម ដែលចែកឋានទៅកាន់បរលោកហើយ ហៅថាបិណ្ឌ ធ្វើបុណ្យដាក់ទានថាបិណ្ឌភ្ជុំបិណ្ឌ ។

មុនថ្ងៃភ្ជុំមួយថ្ងៃ គ្រួសារខ្មែរនៅគ្រប់ទីកន្លែងនាំគ្នាធ្វើនំអន្សម នំគមជាដើមបំរុងយកទៅវត្ត ប្រគេនព្រះសង្ឃឧទ្ទិសកុសល និងសំរាប់ចែកញាតិមិត្ត ។ ឯនៅទីវត្ត ពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ បោសសំអាតទីធ្លាវត្ត សំអាតចេតិយ និងតាក់តែងសាលាបុណ្យឲ្យបានសមរម្យ ។ នៅល្ងាចថ្ងៃ១៤រោច មុនភ្ជុំមួយថ្ងៃមានពិធីពិសេស គឺព្រះសង្ឃចំរើនព្រះបរិត្តនិងទេសនា កន្លែងខ្លះមានធ្វើពិធីអភិសេកព្រះពុទ្ធរូបផង ។ រាល់យប់ក្នុងអំឡុងពេលកាន់បិណ្ឌនិងភ្ជុំបិណ្ឌនោះ ពុទ្ធបរិស័ទបាននាំគ្នាទៅវត្ត ស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តនិងទេសនា ។ រាល់ព្រឹក ពុទ្ធបរិស័ទបានយកចង្ហាន់ទៅរាប់បាត្រនិងវេរប្រគេនព្រះសង្ឃ រួចស្តាប់ព្រះសង្ឃសូត្រដារបង្សុកូលឧទ្ទិសកុសល ។ ពេលព្រលឹមស្រាងៗ គ្រប់វត្តអារាមគេឮសូរព្រះសង្ឃសូត្របរាភវ សូត្រលាយឡំដោយភ្លេងពិណពាទ្យ និងធម៌បទផ្សេងៗកំដរបុណ្យផង ។ មានកន្លែងខ្លះពុទ្ធបរិស័ទក្រោកពីព្រលឹមបាចបាយបិណ្ឌនៅតាមខឿនព្រះវិហារ ដោយគេយល់ថា ពួកប្រេតតែងតែមកពេលល្ងិត រកចំណីបរិភោគ ។ ស្របគ្នាក្នុងន័យនេះដែរ បានជាគេធ្វើបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះខាងរនោចព្រោះគេយល់ថា ពួកប្រេតចេញដើររកចំណីពេលងងឹត ។ ប៉ុន្តែតាមគម្ពីរព្រះពុទ្ធសាសនាផ្នែកព្រះសូត្របញ្ជាក់ថា អ្នកស្លាប់ដែលអាចទទួលផលបាន ដោយសារក្រុមគ្រួសារញាតិមិត្ត ដែលបានធ្វើបុណ្យឧទ្ទិសទៅឲ្យ ដូចជាការធ្វើទានរក្សាសីលជាដើម ជាពិសេសអ្នកដែលអាចទទួលផលបាន គឺពួកមនុស្សសត្វដែលបានទៅកើតជាប្រេត ។

នៅក្នុងពេលកាន់បិណ្ឌនិងភ្ជុំបិណ្ឌនោះព្រះសង្ឃនិងពុទ្ធបរិស័ទតែងតែសូត្រនូវសូត្រមួយហៅថាបរាភវសូត្រ ។ បានជាយកសូត្រនេះមកសូត្រធ្វើជាបទផងព្រោះសូត្រនេះមានប្រយោជន៍ក្នុងការងារប្រចាំថ្ងៃរបស់មនុស្ស ។ គឺជាសូត្រមួយដែលពួកទេវតាទូលសួរព្រះពុទ្ធអំពីធម៌ដែលនាំឲ្យមានសេចក្តីវិនាស ដែលផ្ទុយគ្នាពីមង្គលសូត្រ ដែលពោលអំពីធម៌ ដែលនាំឲ្យមានសេចក្តីចំរើន ។ បរាភវសូត្រធម៌ដែលនាំឲ្យមានសេចក្តីវិនាសមានជាអាទិថា អ្នកស្រឡាញ់ធម៌នាំឲ្យចំរើន អ្នកស្អប់ធម៌នាំឲ្យវិនាស; អ្នកសេពគប់អសប្បុរស អ្នកដេកច្រើននិយាយច្រើន អ្នកមានទ្រព្យច្រើន មិនចិញ្ចឹមមាតាបិតាដែលចាស់ជរា; អ្នកប្រព្រឹត្តល្បែងបីប្រការ ល្បែងស្រីល្បែងស្រាល្បែងភ្នាល់ទាំងឡាយជាដើម ទាំងអស់នេះជាប្រធាននៃសេចក្តីវិនាស ។

បុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ មានខ្លឹមសារជាពិសេសគឺការឧទ្ទិសកុសលជួយរំដោះទុក្ខដល់ញាតិមិត្តក្រុមគ្រួសារ មានមាតាបិតាជាដើម ដែលចែកឋានទៅក្រែងទៅកើតទីណាមួយមានទុក្ខវេទនា ដោយមានអត្ថបទបុរាណខ្មែរពោលថាស្តេចយមរាជបានដោះលែងសត្វនរកឬប្រេតក្នុងឱកាសបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនោះ ឲ្យទៅរកបងប្អូនកូនចៅ ក្រែងធ្វើបុណ្យកុសលឧទ្ទិសឲ្យខ្លួន ។ រហូតមានអត្ថបទខ្លះនិយាយថា បើរកមិនឃើញញាតិមិត្តណាធ្វើបុណ្យឧទ្ទិសឲ្យទេ ក៏យំសោកបោកខ្លួនដោយសេចក្តីស្រេកឃ្លាន ហើយក៏ប្រទេចផ្តាសាដល់ញាតិមិត្តបងប្អូនកូនចៅរបស់ខ្លួន ដែលមានចិត្តអាក្រក់ពុំនឹកនាដល់សេចក្តីទុក្ខវេទនារបស់ខ្លួន ។ ដូច្នេះបុណ្យនេះចាត់ទុកជាបុណ្យឧទ្ទិសកុសលជួយរំលែកទុក្ខ ក្រែងជាតិកំណើតណាមួយបានធ្វើអំពើបាប ហើយធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ ។ បុណ្យនេះមានអត្ថន័យសំខាន់មួយទៀត គឺការពិចារណានូវសង្សារវដ្ត ដែលតែងតែកើតមកហើយ តែងតែស្លាប់ទៅវិញ អាចឲ្យជំរុញទឹកចិត្តលះបង់នូវអំពើបាបហើយសាងតែអំពើល្អ ព្រោះខ្លាចធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិទាំង៤មាននរកជាដើម ។

តាមការស្រាវជ្រាវ បុណ្យនេះពុំដឹងប្រាកដថា កើតឡើងក្នុងសម័យណាទេ នៅសម័យពុទ្ធកាល គេទំនុកបំរុងព្រះសង្ឃដោយបច្ច័យ៤ក្នុងរយៈពេល៣ខែ ដែលព្រះសង្ឃចូលព្រះវស្សានោះតែម្តង ។ ខ្លះថាបុណ្យនេះ យកតាមលំនាំរឿងប្រេតជាញាតិរបស់ព្រះបាទពិម្ពិសារនៅក្នុងគម្ពីរធម្មបទ ដោយមានសេចក្តីដំណាលជាសង្ខេបថា នៅពេលដែលព្រះបាទពិម្ពិសារបាននិមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានមកទទួលចង្ហាន់ ពុំបានតាំងព្រះទ័យឧទ្ទិសកុសលដល់ព្រះញាតិរបស់ព្រះអង្គ ពួកព្រះញាតិដែលទៅកើតជាប្រេត បានបន្លឺសម្លេងយំស្រែកជុំវិញព្រះរាជវាំង ជាសញ្ញាទាមទារផលបុណ្យ ព្រោះខ្លួនមានទុក្ខវេទនាអត់ឃ្លានជាយូរមកហើយ ។ ដោយទូលសួរព្រះពុទ្ធជាម្ចាស់ ថាតើសម្លេងនោះជាសម្លេងអ្វី ? ព្រះពុទ្ធត្រាស់ថា សម្លេងនោះជាសម្លេងពួកប្រេតជាញាតិរបស់ព្រះអង្គ ពួកគេយំស្រែកព្រោះមហារាជពុំបានផ្សាយកុសលដល់ពួកគេ ។ ព្រះបាទពិម្ពិសារបានជ្រាបហេតុការណ៍នេះហើយ ទើបព្រះអង្គប្រញាប់ប្រញាល់ធ្វើបុណ្យដូចគ្នានេះជាលើកទី២ ហើយតាំងចិត្តឧទ្ទិសកុសលដល់ពួកប្រេតជាញាតិ ។ ចាប់ពីពេលនោះមក សម្លេងស្រែកក៏ស្ងាត់បាត់ទៅ ជាភស្តុតាងបញ្ជាក់ថា ពួកប្រេតជាញាតិបានទទួលផលបុណ្យនោះហើយ ។ បុណ្យនេះពុំមែនឧទ្ទិសចំពោះតែសត្វដែលកើតជាប្រេតនោះឡើយ ព្រោះពាក្យថាបេតៈ ជាភាសាបាលី, សំស្ក្រឹតថា ប្រេតៈ ខ្មែរថាប្រេត ប្រែជាសេចក្តីថា អ្នកទៅកាន់បរលោក ឬអ្នកដែលធ្វើមរណកាលទៅកាន់បរលោក ។ ប្រើជានាមសំដៅយកសត្វប្រេតក្នុងអបាយភូមិ ។ ប្រើជាគុណនាមសំដៅយកមនុស្សដែលស្លាប់ទៅហើយ ។

នៅល្ងាចថ្ងៃ១៥រោចខែភទ្របទនៃថ្ងៃភ្ជុំនោះ ប្រជាពលរដ្ឋខ្មែររៀបចំសែនដូនតា ដោយពិធីផ្សេងៗក្រៅព្រះពុទ្ធសាសនាខ្លះ គឺនៅវេលាល្ងាចនោះ មានរៀបកន្ទេលខ្នើយ ក្រាលសំពត់សលើកន្ទេល ដាក់ចំអាបមួយថាស បង្អែមមួយថាស មានក្រាសម្បៀជាដើម ហើយឲ្យកូនចៅចៅច្រូចទឹកលើសំណែននោះ ប្រតិស្ឋអធិដ្ឋានជូនទៅដូនតា ។ លុះព្រឹកឡើងថ្ងៃ១កើខែអស្សុជ មានធ្វើទូកស្រទបចេកដាល់ចំណីលើ អុជទៀនធូបបណ្តែតលើខ្នងទឹកទន្លេស្ទឹងព្រែកឬអូរ តាមស្ថានភាពនៃស្រុកនីមួយៗ បញ្ជូនដូនតាទៅស្រុកវិញ ។ ពិធីទាំងអស់នេះ មកដល់បច្ចុប្បន្ននេះហាក់ដូចជាបាត់បង់ទៅហើយ ពុំសូវមានធ្វើដូចពីដើមទេ អាចមានធ្វើខ្លះនៅតាមជនបទ ។ ទោះបីពិធីនេះក្រៅព្រះពុទ្ធសាសនា ប៉ុន្តែមានន័យរំលឹកគុណាចូលក្នុងន័យព្រះពុទ្ធសាសនា ។ បុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ មានអត្ថន័យសំខាន់ណាស់ក្នុងអារ្យធម៌ខ្មែរក្នុងចំណងសាមគ្គី ភាតរភាព មេត្រីភាព ទោះបីញាតិមិត្តចែកឋានទៅហើយ ក៏នៅតែនឹករលឹកតបគុណជួយរំដោះទុក្ខដែរ ។៚